# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**
**និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**

**លេខៈ០២៧/០៧ របក.អគគ**

## របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ សីហា ឆ្នាំ ២០០៧របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ សីហា ឆ្នាំ ២០០៧ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោង ជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាម បេសកកម្មដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

**១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**

ក. <u>ការងាររដ្ឋបាល</u>

-ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំ ស្តីពីការរៀបចំប្រព័ន្ធសូចនាករសម្រាប់តាមដានការអនុវត្តកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃពុធ ទី០៨ ខែសីហា ឆ្នាំ២០០៧ វេលាម៉ោង ៩.០០ ព្រឹក

-ផ្ញើដីកាអមសេចក្តីថតចម្លងកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ស្តីពីលទ្ធផលសំខាន់ៗនៃការអនុវត្តកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ឆ្នាំ២០០៦ កាលពីថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០០៧

-ផ្ញើលិខិតទៅអភិបាលខេត្តពោធិ៍សាត់ ដើម្បីរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីកម្មវិធីសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០៧ វេលាម៉ោង ៧.៣០ នាទីព្រឹក

-ផ្ញើលិខិតទៅអភិបាលខេត្តកំពង់ចាម ដើម្បីរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធីសកម្មភាពសម្រាប់ អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០០៧ វេលាម៉ោង ៧:៣០ នាទីព្រឹក

-ផ្ញើលិខិតទៅអភិបាលខេត្តមណ្ឌលគីរី ដើម្បីរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីកម្មវិធីសកម្មភាពសម្រាប់ អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០០៧ វេលាម៉ោង ៧.៣០ នាទីព្រឹក

-ផ្ញើបញ្ជីឈ្មោះមន្ត្រីរាជការនៃអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ដែលត្រូវស្នើសុំគ្រឿងឥស្សរិយយសសម្រាប់ឆ្នាំ ២០០៧ ទៅទីស្តីការគណៈរដ្ឋមន្ត្រី

-បានរៀបចំសេចក្តីសម្រេចស្តីពីសមាសភាពក្រុមការងារបច្ចេកទេសតុលាការគំរូ

-លិខិតស្នើកែខ្លឹមសារចំណុច ៥.១ នៃសារាចរ ស្តីពីនីតិវិធី និងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តិផ្សេងៗ

-ផ្ញើដីកាអមរបាយការណ៍កិច្ចប្រជុំស្តីពីការអភិវឌ្ឍន៍ប្រព័ន្ធសូចនាករ និងតាមដានរួម លេខ ០២២/០៧ របក.អសអ កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៧ និង លេខ ០២៣/០៧ របក.អសអ កាលពីថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០០៧

-ផ្ញើលិខិតឯកភាពចំពោះការស្នើឱ្យមន្ត្រីជំនាញបីរូបរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច មកធ្វើការស្រាវជ្រាវលើផ្នែកពាក់ព័ន្ធនឹងយុទ្ធសាស្រ្តកំណែទម្រង់ច្បាប់ និងតុលាការ

-ផ្ញើលិខិតស្នើនៅតាមក្រសួងនានា ដើម្បីជួយបំពេញបញ្ជីរាយឈ្មោះច្បាប់ Law Catalogue និង ព័ត៌មានទាក់ទងនឹងអង្គភាពនីតិកម្មរបស់ក្រសួង

-ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំអនុក្រុមទី ១ ការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០០៧ វេលាម៉ោង ៨.០០ ព្រឹក

-ផ្ញើលិខិតអញ្ជើញចូលរួមកិច្ចប្រជុំស្តីពីការរៀបចំ និងអនុវត្តគម្រោងតុលាការគំរូនៅកម្ពុជា នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៧ វេលាម៉ោង ៨. ៣០ នាទីព្រឹក។

ខ. <u>ការងារកំណែទម្រង់</u>

-រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០០៧ វេលាម៉ោង ២:៣០ នាទីរសៀល នៅទីស្តីការគណៈរដ្ឋមន្ត្រី

-រៀបចំកិច្ចប្រជុំស្តីពីការរៀបចំប្រព័ន្ធសូចនាករ សម្រាប់តាមដានការអនុវត្តកំណែទម្រង់ច្បាប់ និង តុលាការ នៅថ្ងៃពុធ ទី០៨ ខែសីហា ឆ្នាំ២០០៧ វេលាម៉ោង ៩:០០ ព្រឹក

-កិច្ចប្រជុំអនុក្រុមទី ១ ការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០០៧ វេលាម៉ោង ៨:០០ ព្រឹក

-ប្រជុំអង្គភាពគ្រប់គ្រងគម្រោង ពិភាក្សាលើការរៀបចំ Website របស់អង្គភាព នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៧

-ប្រជុំពង្រឹងសមត្ថភាពមន្ត្រីអង្គភាពគ្រប់គ្រងគម្រោង នៅថ្ងៃទី ២២ ខែសីហា ឆ្នាំ២០០៧។

គ. <u>ផ្សេងៗ</u>

-ចូលរួមពិធីប្រគល់វិញ្ញាបនប័ត្រមេធាវីនៅសាលាភូមិន្ទរដ្ឋបាល ក្រោមអធិបតីភាព ឯកឧត្តម សុខ អាន

-ពិនិត្យ កែសម្រួលសេចក្តីព្រាងសារាចរស្តីពីនីតិវិធី និងវិធាននៃការតាក់តែងលិខិត-បទដ្ឋាន

-ចូលរួមក្នុងពិធីបើកសំបុត្រជ្រើសរើសអ្នកជំនាញផ្នែករៀបចំប្រព័ន្ធទិន្នន័យការ បណ្តុះ-បណ្តាល សិទ្ធិមនុស្ស នៅមូលដ្ឋាន នៅកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ UNDP នៅថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០៧

-ចូលរួមប្រជុំរៀបចំគោលការណ៍ភាពជាដៃគូជាមួយប្រទេសអង់គ្លេស នៅក្រុមប្រឹក្សា-អភិវឌ្ឍន៍កម្ពុជា CDC នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧។

២-សន្និដ្ឋាន

ក្នុងខែ កក្កដា ឆ្នាំ ២០០៧ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាព សម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមាន អង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានបន្តកិច្ចការពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី សកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ទៅតាមអាទិភាព ដែលបាន កំណត់ ដោយ ផ្តោតជាសំខាន់ទៅលើការរៀបចំការអនុវត្តគម្រោង ស្តីពីការពង្រីកបន្ថែម តុលាការគំរូ និងការរៀបចំ ប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ។

**៣-ទិសដៅអនុវត្តក្នុងខែបន្ត**

-រៀបចំកិច្ចប្រជុំស្តីពីការរៀបចំ និងអនុវត្តគម្រោងតុលាការគំរូនៅកម្ពុជា នៅថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០០៧ នៅអង្គភាពគ្រប់គ្រងគម្រោង

-រៀបចំសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារប្រព័ន្ធសូចនាករ និងតាមដានរួម

-រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែ-ទម្រង់ច្បាប់ និង តុលាការ នៅខេត្តបណ្តាខេត្តនានា

-បន្តធ្វើបច្ចុប្បន្នភាពកម្មវិធីសកម្មភាព និងបញ្ជីគម្រោង តាមរយៈការប្រជុំពិភាក្សាតាម-អនុក្រុម Sub-Group/TWG

-សុំយោបល់អនុក្រុមនានា ដើម្បីបំពេញរបាយការណ៍ជឿនលឿនស្នើដោយ GDCC សម្រាប់ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០០៧។

*រាជធានី ភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៧*

**អ្នកធ្វើរបាយការណ៍**

ហ៊្សឹង សុកុល

**បានឃើញ និងឯកភាព**

**នាយកអង្គភាពគ្រប់គ្រងគម្រោង**

ស៊ុយ ម៉ុងលាង